# ការផ្តល់ជំនួយសហរដ្ឋអាមេរិកមកឱ្យប្រទេសកម្ពុជា
# ពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៦៣

*ស្នាដៃរួមរបស់អ្នកស្រាវជ្រាវផ្នែកប្រវត្តិវិទ្យា និង វិទ្យាសាស្ត្រនយោបាយ នៃ*
*រាជបណ្ឌិត្យសភាកម្ពុជា៖*
*លោក* **សួ ប៉ុណ្ណារ៉ាត់** *( បេក្ខជនបណ្ឌិតផ្នែកប្រវត្តិសាស្ត្រ)*
*លោក* **សុខ ស៊ីណា** *( បណ្ឌិតផ្នែកប្រវត្តិសាស្ត្រ)*
*លោក* **អាត ឡៀង** *( បេក្ខជនបណ្ឌិតផ្នែកប្រវត្តិសាស្ត្រ)*

## សេចក្តីផ្តើម

ប្រទេសកម្ពុជាជាអតីតប្រទេសមួយ ដែលធ្លាប់ស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំងពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ១៩៥៣។ សម្តេចព្រះនរោត្តម សីហនុ បានធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជូនជាតិមាតុភូមិពីបារាំងប្រកបដោយជោគជ័យនៅឆ្នាំ១៩៥៣។ ចំណែកនៅប្រទេសវៀតណាមឯណោះវិញលោក ហូ ជីមិញ ក៏បានបង្កើតចលនាតស៊ូកុម្មុយនីស្តវៀតណាមដើម្បីទាមទារឯករាជ្យពីប្រទេសបារាំងផងដែរ។ ចលនាតស៊ូកុម្មុយនីស្តវៀតណាមបានធ្វើឱ្យបារាំងទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរនៅសមរភូមិឌៀនបៀនភូនាឆ្នាំ១៩៥៤។

ដោយមើលឃើញថា ប្រទេសបារាំងមិនអាចទប់ទល់នឹងការរីករាលដាល នៃចលនាតស៊ូ កុម្មុយនីស្តវៀតណាម សហរដ្ឋអាមេរិកបានពង្រីកនយោបាយការទូតជាអន្តរជាតិរបស់ខ្លួនចូលមកក្នុងតំបន់ឥណ្ឌូចិន ។ នៅឆ្នាំ១៩៥៤ សហរដ្ឋអាមេរិកបានបង្កើតអង្គការសន្ធិសញ្ញាការពារការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍ ហៅកាត់ថា អង្គការសេអាតូ (SEATO)។

ចំពោះប្រទេសកម្ពុជា បន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបារាំងនៅឆ្នាំ១៩៥៣ មកយើងសង្កេតឃើញថា កម្ពុជាត្រូវប្រឈមនឹងបញ្ហាជាច្រើន ជាពិសេសវិស័យសេដ្ឋកិច្ច។ សេដ្ឋកិច្ចកម្ពុជានាពេលនោះនៅទន់ខ្សោយមិនមានលទ្ធភាពអភិវឌ្ឍប្រទេសជាតិបានដោយខ្លួនឯងទាំងស្រុងនោះឡើយ។ អាស្រ័យហេតុនេះ កម្ពុជាត្រូវស្វែងរកជំនួយពីបរទេសដើម្បីយកមកអភិវឌ្ឍន៍សង្គមជាតិរបស់ខ្លួនឡើងវិញ។

ស្របគ្នានោះ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានប្រកាសទទួលស្គាល់ប្រទេសកម្ពុជានៅឆ្នាំ១៩៥០។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៥០ ឯកអគ្គរដ្ឋទូតដំបូងរបស់សហរដ្ឋអាមេរិកគឺលោក Donald Heath បានមកថ្វាយសារតាំងដល់ព្រះមហាក្សត្រខ្មែរសម្តេចព្រះនរោត្តម សីហនុ។

ចាប់ពីពេលនោះមកសហរដ្ឋអាមេរិកបានចាប់ផ្តើមផ្តល់ជំនួយមកឱ្យប្រទេសកម្ពុជា ដែលនៅក្នុងបរិបទនោះប្រទេសកម្ពុជាស្ថិតនៅក្នុងភូមិសាស្ត្រនយោបាយមួយដ៏សំខាន់ សម្រាប់នយោបាយការបរទេសនៃប្រទេសមហាអំណាច ជាពិសេសគឺសហរដ្ឋអាមេរិកដែលមានបំណងទប់ទល់នឹងការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅឥណ្ឌូចិន។

នៅក្នុងទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិក តើសហរដ្ឋអាម៉េរិកបានផ្តល់ជំនួយមកឱ្យប្រទេសកម្ពុជាពីឆ្នាំ១៩៥០-១៩៦៣ តាមរូបភាពយ៉ាងដូចម្តេច? ហើយជំនួយទាំងនោះត្រូវបានគេយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍន៍លើវិស័យសំខាន់ៗអ្វីខ្លះ?

## ផ្នែកទី ១. ស្ថានភាពនយោបាយកម្ពុជា និង ពិភពលោកក្រោយសង្គ្រាមលោកលើកទី២

ដោយសារពិភពលោកស្ថិតក្នុងស្ថានភាពនៃសង្គ្រាមត្រជាក់ដែលជាដំណាក់កាល នៃការប្រឈមរវាងមនោគមវិជ្ជាសេរី និង កុម្មុយនីស្ត ពិភពលោកត្រូវជួបប្រទះនូវការប្រយុទ្ធដណ្តើមឥទ្ធិពលគ្នារវាងប្រទេសមហាអំណាចលោកសេរី (សហរដ្ឋអាម៉េរិក) និង ប្រទេសមហាអំណាចកុម្មុយនីស្ត (សហភាពសូវៀត)។ នៅពេលនោះប្រទេសនានាក្នុងសកលលោក ជាពិសេសប្រទេសអតីតក្រោមអាណានិគមក្រោយទទួលបានឯករាជ្យ ប្រទេសទាំងនោះតែងស្វែងរកជំនួយពីបរទេសដើម្បីយកមកអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន។

ការស្វែងរកជំនួយនេះ យើងសង្កេតឃើញថា ប្រទេសទាំងនោះភាគច្រើនតែងទទួលរងនូវការប្រទាញប្រទង់ឥទ្ធិពលពីសំណាក់ប្រទេសមហាអំណាចធំៗទាំងពីរ។ ស្ថានភាពបែបនេះដួនកាលធ្វើឱ្យប្រទេសដែលទទួលជំនួយទាំងនោះធ្លាក់ចូលទៅក្នុងសង្គ្រាមថែមទៀតផង។

### I-ការប្រែប្រួលស្ថានភាពនយោបាយនៅឥណ្ឌូចិនក្រោយសង្គ្រាមលោកលើកទី២

#### ១-ប្រទេសកម្ពុជាក្រោយសង្គ្រាមលោកលើកទី២

##### ក-ការកកើតចលនាតស៊ូទាមទារឯករាជ្យកម្ពុជា

ចំណែកស្ថានការណ៍នយោបាយនៅឥណ្ឌូចិននាក្រោយសង្គ្រាមលោកលើកទី២ យើងសង្កេតឃើញថា បន្ទាប់ពីប្រទេសជប៉ុនបានចាញ់សង្គ្រាមនាឆ្នាំ១៩៤៥ មហាអំណាចអាណានិគមបារាំងបានចូលមកកាន់កាប់តំបន់ឥណ្ឌូចិនឡើងវិញ។ ក្នុងដំណាក់កាលថ្មីនេះស្ថានភាពទូទៅនៅតំបន់នេះមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ការប្រែប្រួលនោះគឺនៅក្នុងប្រទេសកម្ពុជា វៀតណាម ឡាវ សុទ្ធតែមានចលនាតស៊ូទាមទារឯករាជ្យពីបារាំង។

នៅកម្ពុជាបារាំងមិនអាចមកត្រួតត្រាដូចពេលមុនសង្គ្រាមលោកបានតទៅទៀតឡើយ ហេតុនេះបារាំងបានកែប្រែយុទ្ធសាស្ត្រគ្រប់គ្រងគឺនៅឆ្នាំ១៩៤ ប្រទេសបារាំងបានយល់ព្រមទទួលយកកិច្ចព្រមព្រៀងបណ្តោះអាសន្ន (Modus Vivendi) ដែលសម្តេច ស៊ីសុវត្ថិ មុនីរ៉េត ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា និង ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្របានចុះហត្ថលេខាជាមួយនឹងតំណាងរបស់រដ្ឋាភិបាលបារាំង។ ដោយមើលឃើញនូវវិសមភាពនៃកម្លាំងសេដ្ឋកិច្ចក៏ដូចជាកម្លាំង យោធារវាងប្រទេសបារាំង និង កម្ពុជា ហើយដើម្បីចៀសវាងនូវការបង្ហូរឈាមផងនោះព្រះមហាក្សត្រកម្ពុជាសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានជ្រើសរើសរកដំណោះស្រាយតាមរយៈកិច្ចព្រមព្រៀងសម្របសម្រួលជាមួយនឹងបារាំង។

នៅពេលនោះបារាំងបានអនុញ្ញាតឱ្យកម្ពុជាបង្កើតគណបក្សនយោបាយ ដើម្បីរៀបចំការបោះឆ្នោតបង្កើតជារដ្ឋសភាជាតិ។ រដ្ឋធម្មនុញ្ញកម្ពុជាលើកដំបូងត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧។

រយៈពេលបីឆ្នាំក្រោយមកគឺនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ដែលមានសម្ដេចស៊ីសុវត្ថិ មុនីពង្ស ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្របានចុះហត្ថលេខាជាមួយនឹងតំណាងរបស់រដ្ឋាភិបាលបារាំង នៅក្រុងប៉ារីស។ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ប្រទេសកម្ពុជា។ ឯករាជ្យនេះគឺ មានតែនៅក្នុងច្បាប់ប៉ុណ្ណោះ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែងនោះប្រទេសបារាំងនៅបន្តកាន់កាប់ក្រសួង សំខាន់ៗរបស់កម្ពុជាដដែល ដូចជា វិស័យតុលាការ នគរបាល យោធា កិច្ចការ បរទេស សេដ្ឋកិច្ច ជាដើម។ ហេតុដូច្នេះហើយទើបសម្ដេចព្រះនរោត្តម សីហនុ ព្រះអង្គទ្រង់បានសន្យានៅក្នុងព្រះរាជ សាសន៍របស់ព្រះអង្គទៅកាន់ជនរួមជាតិនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ថា ព្រះអង្គនឹងទាមទារ ឯករាជ្យបរិបូរណ៍ឱ្យបានក្នុងរយៈពេលបីឆ្នាំយ៉ាងយូរ។ នៅឆ្នាំ១៩៥២ ព្រះមហាក្សត្រកម្ពុជាចាប់ផ្ដើម ទាមទារឯករាជ្យឱ្យបានមួយរយភាគរយដែលកិច្ចការនេះហៅថា ព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ បរិបូរណ៍នៃកម្ពុជា។

ក្រៅពីការតស៊ូនៅក្នុងប្រទេស សម្ដេចព្រះនរោត្តម សីហនុ បានយាងចេញទៅតស៊ូទាមទារ ឯករាជ្យតាមផ្លូវការទូត គឺនៅលើឆាកអន្តរជាតិក្នុងទិសដៅដើម្បីឱ្យពិភពលោកបានដឹងនូវគោល បំណងពិតប្រាកដរបស់ប្រជាជនកម្ពុជា។ ជាដំបូងព្រះអង្គបានយាងចេញពីប្រទេសកម្ពុជាឆ្ពោះទៅ កាន់ប្រទេសបារាំងនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣។ ជាបន្តបន្ទាប់ព្រះអង្គបានផ្ញើព្រះសារលិខិតមួយ ច្បាប់ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៥៣ ពីក្រុង ឡាណាពូល (La Napoule) ជូនទៅលោកប្រធានាធិបតី បារាំង វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol) ។ នៅក្នុងព្រះសារលិខិតនោះគឺភាគី កម្ពុជាបាន ទាម ទារឱ្យបារាំងប្រគល់ឯករាជ្យឱ្យបានទូលំទូលាយថែមទៀត។ នៅក្នុងសារលិខិតនោះដែរក៏បាន ភ្ជាប់ទៅជាមួយនូវសេចក្ដីរាយការណ៍មួយច្បាប់ដែលបញ្ជាក់ជូនពីសម្ពាធផ្សេងៗ ដែលនាំឱ្យមានការ ទាមទារឯករាជ្យ និង ជូននូវគ្រោងការនៃពិធីផ្ទេរអំណាចនានាមកឱ្យកម្ពុជា។

ក្រោយមកទៀតសម្ដេចព្រះនរោត្តម សីហនុ ព្រះអង្គបានផ្ញើព្រះសារលិខិតចំនួនពីរច្បាប់ទៀត គឺមួយច្បាប់ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣ និង មួយច្បាប់ទៀតចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៥៣ ជូនទៅលោកប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល។ នៅក្នុងខ្លឹមសារនៃព្រះសារលិខិតនោះព្រះអង្គ បានសុំឱ្យភាគីបារាំងសម្រេចអំពីការប្រគល់ឯករាជ្យកម្ពុជាឱ្យបានឆាប់រហ័ស។ ដោយការតស៊ូតាម រយៈការទូតនៅប្រទេសបារាំងមិនទទួលបានលទ្ធផលជាវិជ្ជមាននោះ សម្ដេចព្រះនរោត្តម សីហនុ ព្រះអង្គបានសម្រេចយាងចាកចេញពីប្រទេសបារាំងឆ្ពោះទៅកាន់ប្រទេសកាណាដា និង សហរដ្ឋ អាម៉េរិក នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣។

អ្នកដែលបានអមព្រះរាជដំណើរយាងទៅកាន់សហរដ្ឋអាម៉េរិក និង ប្រទេសកាណាដារបស់ សម្ដេចព្រះនរោត្តម សីហនុ មាន ៖

១-ឯកឧត្តម ឡេង ង៉ែត ទីប្រឹក្សាផ្ទាល់របស់ព្រះអង្គ

២-ឯកឧត្តម ទី គឹមសួរ អគ្គលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី។

មូលហេតុដែលនាំឱ្យព្រះអង្គយាងទៅកាន់ក្រុងម៉ុងរ៉េអាល់ (Monréal) ប្រទេសកាណាដា ព្រោះប្រទេសកាណាដាស្ថិតនៅជាប់នឹងសហរដ្ឋអាម៉េរិក ហើយប្រជាជនក្រុងកេបិច (Québec) មាន គំនិតប្រហាក់ប្រហែលនឹងជនជាតិបារាំង ហេតុនេះគេមិនអាចព្រងើយកន្តើយមិនយកចិត្តទុកដាក់ពី ការគំរាមកំហែងរបស់កុម្មុយនីស្តនៅឥណ្ឌូចិននោះឡើយ ។ នៅសហរដ្ឋអាម៉េរិកព្រះរាជសាសន៍ ដែល

បានចុះផ្សាយក្នុងកាសែតញូវយ៉កថែម (New York Times) ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៥៣ បានធ្វើឱ្យសាធារណមតិអាម៉េរិក និង សកលលោកមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ សម្តេចព្រះនរោត្ដម សីហនុ បានមានព្រះបន្ទូលថា បើប្រទេសបារាំងមិនព្រមប្រគល់ឯករាជ្យមកឱ្យកម្ពុជាគ្រោះថ្នាក់មួយដ៏ពិតប្រាកដ ដោយប្រជារាស្ត្រកម្ពុជាក្រោកឈរប្រឆាំងនឹងរបបព្រះអង្គ ហើយពួកគេនឹងទៅចុះចូលជាមួយនឹងចលនាវៀតមិញដឹកនាំដោយពួកកុម្មុយនីស្ត។ កត្តាទាំងនេះជាហេតុនាំឱ្យរដ្ឋាភិបាលបារាំងបង្ខំចិត្តយល់ព្រមចរចាជាមួយនឹងភាគីកម្ពុជា។ មុននឹងវិលត្រឡប់ពីសហរដ្ឋអាម៉េរិក ឆ្ពោះមកប្រទេសកម្ពុជា សម្តេចព្រះនរោត្តម សីហនុ បានយាងទៅកាន់ប្រទេសជប៉ុន។ នៅទីនោះ ព្រះអង្គមិនបានធ្វើសកម្មភាពអ្វីជាធំដុំឡើយ។ ដើម្បីព្រះអង្គបានជួបប្រាស្រ័យជាមួយនឹងសហការី របស់ព្រះអង្គ សម្តេចព្រះនរោត្តម សីហនុ បានយាងចាកចេញពីប្រទេសជប៉ុនមកកាន់ក្រុងភ្នំពេញ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣។

បន្ទាប់មកទៀតព្រះអង្គបានយាងទៅកាន់ប្រទេសថៃ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៣។ នៅក្រុងបាងកក ស្តេចភូមីពុល មិនបានមកទទួលព្រះអង្គឡើយ។ រដ្ឋមន្ត្រីការបរទេសថៃបានធ្វើឱ្យព្រះអង្គដឹងថាប្រទេសថៃមិនផ្តល់នូវសមានចិត្តចំពោះព្រះអង្គឡើយ ព្រោះសំខាន់បំផុតគេមិនចង់ឱ្យមានការលំបាកក្នុងផ្នែកនយោបាយ និង ការទូតជាមួយនឹងប្រទេសបារាំង។ រដ្ឋាភិបាលថៃបានប្រកាន់ឥរិយាបថហាមឃាត់សម្តេចព្រះនរោត្តម សីហនុ មិនឱ្យធ្វើនយោបាយ ហើយគេមិនអនុញ្ញាតឱ្យព្រះអង្គស្នាក់នៅគេហដ្ឋានរបស់ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅក្រុងបាងកកទៀតផងដោយគេបានយកលេសថា ព្រះអង្គគ្រាន់តែជាជននិរទេសម្នាក់ប៉ុណ្ណោះ។

ក្រោយពីទទួលបានការយកចិត្តទុកដាក់ពីបណ្តារដ្ឋនានាមក សម្តេចព្រះនរោត្តម សីហនុ បានយាងត្រឡប់មកកាន់កម្ពុជាវិញ ប៉ុន្តែ ព្រះអង្គបានទៅតាំងបញ្ជាការនៅក្នុងតំបន់ស្វយ័តដែលមានខេត្តសៀមរាប បាត់ដំបង និង កំពង់ធំ។ គួររម្លឹកផងដែរថា ប្រទេសកម្ពុជាបានទទួលស្វ័យភាពផ្នែកសឹកនៅក្នុងខេត្តសៀមរាប និង កំពង់ធំឆ្នាំ១៩៤៩ ហើយខេត្តបាត់ដំបងបានទទួលស្វយ័តភាពផ្នែកសឹកនៅឆ្នាំ១៩៥២ នេះជាមធ្យោបាយមួយទៀតសម្រាប់ជាយុទ្ធសាស្ត្រក្នុងការទាមទារឯករាជ្យរបស់កម្ពុជា។ ចាប់ពីឆ្នាំ១៩៥៣ មកប្រទេសបារាំងបានចាប់ផ្តើមប្រគល់នូវស្ថាប័នសំខាន់ៗមកឱ្យកម្ពុជាដែលមានលំដាប់លំដោយដូចខាងក្រោម ៖

- បារាំងបានចុះហត្ថលេខានៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ ស្តីពីការផ្ទេរអំណាចតុលាការ និង ប៉ូលីសមកឱ្យកម្ពុជា។
- ចំពោះអធិបតេយ្យភាពការទូត ក៏ទទួលបានពេញលក្ខណៈផងដែរតាមរយៈការប្តូរលិខិតរវាង រដ្ឋាភិបាលបារាំង និង រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ១៩៥៣ ដែលបានបញ្ជូន តាមរយៈលោកឧត្តមស្នងការនៃសាធារណរដ្ឋបារាំងលេខ ៣៩៣ R ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ១៩៥៣។
- ចុងក្រោយបង្អស់បារាំងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ការប្រគល់អំណាចយោធា ក្នុងប្រទេសកម្ពុជាទាំងមូលមកឱ្យកម្ពុជាវិញ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ១៩៥៣។ ដោយទទួលបាននូវជ័យជម្នះទាំងស្រុងនេះហើយទើបសម្តេចព្រះនរោត្ដម សីហនុព្រះអង្គបានយាងចេញពីតំបន់ស្វយ័ត ឆ្ពោះមកកាន់ក្រុងភ្នំពេញវិញ នៅ

ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ នៅមុខព្រះបរមរាជវាំងនាថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ មានប្រារព្ធពិធីនៃការផ្ទេរអំណាចទាំងស្រុងរបស់ប្រទេសបារាំងមកឱ្យប្រទេស កម្ពុជា។ នៅពេលនោះលោកឧត្តមសេនីយ៍បារាំង ដឺឡង់ ក្លាដ (de Langlade) បានថ្វាយនូវ បញ្ជាការរបស់លោកចំពោះសម្តេចព្រះនរោត្តម សីហនុ។

## ២-ការប្រកាន់យកនយោបាយអព្យាក្រឹតរបស់កម្ពុជា

បន្ទាប់ពីប្រទេសជាតិទទួលបានឯករាជ្យបរិបូរណ៍នាឆ្នាំ១៩៥៣ មក កម្ពុជាត្រូវជ្រើសរើសយកមាគ៌ាមួយក្នុងចំណោមផ្លូវបំបែកបី ទីមួយ ការប្រកាន់យករបបសេរី ទី២ ការប្រកាន់យករបបសង្គមនិយម និង ទី៣ ការប្រកាន់យកនយោបាយអព្យាក្រឹត។ ការដែលនាំឱ្យមានការជ្រើសរើសផ្លូវច្រើនបែបនេះ ព្រោះថា ស្ថានភាពសកលលោកនាបរិបទនោះគឺត្រូវបានទទួលរងនូវឥទ្ធិពលមនោគមវិជ្ជាពីរធំៗ គឺមនោគមវិជ្ជាសេរីដែលមានសហរដ្ឋអាម៉េរិកជាតំណាង និង មនោគមវិជ្ជាកុម្មុយនីស្តដែលមានសហភាពសូវៀតជាតំណាង។ នៅក្នុងសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ស្តីពីការបញ្ឈប់សង្គ្រាមនៅឥណ្ឌូចិនតំណាងគណៈប្រតិភូកម្ពុជាដែលបានទៅចូលរួមក្នុងសន្និសីទនោះបានបង្ហាញជំហររបស់ខ្លួនថា កម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រឹត។ នៅឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តម សីហនុ ព្រះអង្គក៏បានប្រកាសជាផ្លូវការក្នុងសន្និសីទនាក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ីស្តីពី ប្រជាជាតិអាស៊ី-អាហ្វ្រិកថា កម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រឹតសម្រាប់ធ្វើជាមូលដ្ឋានគ្រឹះនៃនយោបាយការបរទេសរបស់ខ្លួននៅក្នុងឆាកអន្តរជាតិ។ ការដែលប្រកាន់យកនយោបាយអព្យាក្រឹតគឺកម្ពុជាមានលទ្ធភាពអាចធ្វើទំនាក់ទំនងជាមួយនឹងប្រទេសមហាអំណាចសេរី និង ប្រទេសមហាអំណាចកុម្មុយនីស្តក៏ដូចជាប្រទេសនានានៅទូទាំងសកលលោក។

ការប្រកាន់យកនយោបាយនេះ នៅគ្រាដំបូងកម្ពុជាគ្រាន់តែបានបង្ហាញឱ្យប្រជាជនកម្ពុជា និង ពិភពលោកបានដឹងតែតាមរយៈសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ និង សន្និសីទបានឌុង ឆ្នាំ ១៩៥៥ ជាដើម។ លុះមកដល់ឆ្នាំ១៩៥៧ ទើបនយោបាយអព្យាក្រឹតកម្ពុជាបានប្រកាសជាផ្លូវច្បាប់តាមព្រះរាជក្រមលេខ២៣២ ន.ស. ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៥៧។ នៅក្នុងមាត្រាទី១ នៃច្បាប់នេះបានចែងថា ព្រះរាជាណាចក្រកម្ពុជាជាប្រទេសអព្យាក្រឹត។ តាមខ្លឹមសារនៃច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ព្រះរាជាណាចក្រកម្ពុជាពុំត្រូវការចងសម្ព័ន្ធមិត្រយោធា ឬ ទាក់ទងខាងផ្លូវគំនិតជាមួយនឹងបរទេសទេ ព្រះរាជាណាចក្រកម្ពុជាពុំបង្កសង្គ្រាមប្រឆាំងនឹងបរទេសណាមួយឡើយ។ នៅក្នុងមាត្រាទី២ បានបញ្ជាក់បន្ថែមទៀតថា ក្នុងករណីដែលបរទេសណាមួយមកបង្កសង្គ្រាមប្រឆាំងមកលើព្រះរាជាណាចក្រកម្ពុជា ៗមានសិទ្ធិនឹង ៖

- ការពារខ្លួនដោយអាវុធ
- អំពាវនាវដល់អង្គការសហប្រជាជាតិ
- អំពាវនាវដល់ប្រទេសមហាអំណាចណាដែលជាមិត្ត[1]។

ដូច្នេះចាប់ពីពេលនោះមកយើងឃើញថា នយោបាយអព្យាក្រឹតបានក្លាយជាមូលដ្ឋានគ្រឹះនៃនយោបាយការបរទេសរបស់កម្ពុជានាសម័យសង្គមរាស្ត្រនិយម។

[1] រាជកិច្ចលេខ២១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៧ ទំព័រ៦៣៣៧-៦៣៣៨

### ៣-ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាមេរិក

នៅសម័យក្រោយសង្គ្រាមលោកលើកទី២ ទំនាក់ទំនងរវាងប្រទេសកម្ពុជា និង សហរដ្ឋអាមេរិកចាប់ផ្តើមមានការប្រែប្រួលស្របពេលដែលកងទ័ពរបស់លោកម៉ៅ សេទុង ជិតទទួលបានជ័យជម្នះទាំងស្រុងនៅប្រទេសចិន ហើយកងទ័ពវៀតមិញប្រឆាំងនឹងអាណានិគមបារាំងកាន់តែមានប្រៀបខ្លាំងឡើងៗនៅវៀតណាមខាងជើង។ ក្នុងពេលដែលគោលនយោបាយការបរទេសរបស់សហរដ្ឋអាមេរិកបានផ្តោតទៅលើការរីករាលដាលចលនាកុម្មុយនីស្តនៅភូមិភាគអាស៊ីអាគ្នេយ៍ ទំនាក់ទំនងរវាងកម្ពុជា-សហរដ្ឋអាមេរិកក៏ចាប់ផ្តើមមានសារសំខាន់។

ប្រទេសកម្ពុជា វៀតណាម និង ឡាវបង្កើតបាននូវអ្វីដែលបារាំងហៅថា ឥណ្ឌូចិនតាំងពីចុង ស.វ.ទី១៩។ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ទឹកដីអាស៊ីអាគ្នេយ៍ភាគច្រើនត្រូវបានកាន់កាប់ដោយកងទ័ពជប៉ុន។ បារាំងបានបន្តកាន់កាប់ឥណ្ឌូចិនឡើងវិញនៅក្រោយសង្គ្រាមលោកលើកទី២ ប៉ុន្តែនៅពេលនោះប្រជាជនកម្ពុជាចាប់ផ្តើមមានគំនិតចង់បានឯករាជ្យ។ បន្ទាប់មកសហរដ្ឋអាមេរិកបានទទួលស្គាល់ប្រទេសកម្ពុជានៅឆ្នាំ១៩៥០។ សហរដ្ឋអាមេរិកបានបង្កើតទំនាក់ទំនងការទូតដោយផ្ទាល់របស់ខ្លួនជាលើកដំបូងជាមួយនឹងប្រទេសកម្ពុជា នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៥០ ដោយបានតែងតាំងលោក Donald R. Heath ឱ្យធ្វើតំណាងវិសាមញ្ញ និង ពេញសមត្ថភាព។ លោក Donald R. Heath បានថ្វាយសារតាំងព្រះបាទ នរោត្តម សីហនុ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៥០។ ការិយាល័យតំណាងសហរដ្ឋអាមេរិកបានបើក ឡើងនៅក្រុងភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៥០។ នៅពេលនោះសណ្ឋាគារឡឺរ៉ូយ៉ាល់ជាកន្លែង ធ្វើការដំបូងរបស់ស្ថានទូតសហរដ្ឋអាមេរិក។ ការិយាល័យតំណាងទូតត្រូវបានដំឡើងឱ្យទៅជាស្ថាន ឯកអគ្គរដ្ឋទូតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥២។ នៅពេលនោះលោក Donald R. Heath បានក្លាយជាឯកអគ្គរដ្ឋទូតដំបូងគេបង្អស់របស់សហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា។ លោក នង គឹមនី ជាទូតតំណាងដំបូងគេរបស់កម្ពុជាប្រចាំនៅសហរដ្ឋអាមេរិកបានសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយរបស់សហរដ្ឋអាមេរិក។

បន្ទាប់ពីសន្និសីទក្រុងហ្សឺណែវស្តីពី ការបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន លោក Robert McClintock បានក្លាយជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅប្រទេសកម្ពុជា ដោយលោកបានថ្វាយសារតាំងដល់ព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ នាថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៥៤។ សម្តេចព្រះនរោត្តម សីហនុ បានបណ្តោះឱ្យមានទំនាក់ទំនងជាមិត្តភាពរបស់កម្ពុជាជាមួយប្រទេសលោកខាងលិច និង ប្រទេសកុម្មុយនីស្ត ។ សហរដ្ឋអាមេរិកមានការភ័យខ្លាចថា កងទ័ពកម្ពុជាមិនមានសមត្ថភាពពេញលេញក្នុងការទប់ទល់នឹងកងទ័ពកុម្មុយនីស្តនោះ ដូច្នេះសហរដ្ឋអាមេរិកបានចាប់ផ្តើមធ្វើការជាមួយនឹងកម្ពុជាដើម្បីបង្កើនជំនួយយោធារបស់ខ្លួនមកកម្ពុជា។

### ៤-ការទទួលយកជំនួយសហរដ្ឋអាមេរិកពីសំណាក់ប្រទេសកម្ពុជា

បន្ទាប់ពីបានទទួលស្គាល់ប្រទេសកម្ពុជានៅឆ្នាំ១៩៥០ មកសហរដ្ឋអាមេរិកបានចាប់ផ្តើមរៀបចំគម្រោងផ្តល់ជំនួយមកឱ្យប្រទេសកម្ពុជា។ ជំនួយទាំងនោះបានផ្តោតទៅលើវិស័យសំខាន់ពីរ គឺ ជំនួយផ្នែកស៊ីវិល និង យោធា ។ ជំនួយទាំងនេះបានទទួលរហូតមកដល់ឆ្នាំ១៩៦៣ ទើបកម្ពុជាបដិសេធលែងទទួលយក។

#### ក-ជំនួយផ្នែកស៊ីវិល

នៅឆ្នាំ១៩៥៥ គេបានបង្កើតកម្មវិធីជំនួយដែលមានទឹកប្រាក់ចំនួន៥០ លានដុល្លារក្នុងមួយឆ្នាំ។ ជំនួយនេះគេផ្តោតទៅលើការជំរុញដំណើរជឿនលឿនវិស័យសេដ្ឋកិច្ច និង សង្គមប្រយោជន៍កែលម្អ និង ពង្រីកការអប់រំសាធារណៈ បង្កើនគុណភាព និង បរិមាណផលិតផលកសិកម្ម លើកកម្ពស់ផ្នែកសុខភាពសាធារណៈ។ ជំនួយសហរដ្ឋអាម៉េរិកបានជួយបណ្តុះបណ្តាលគ្រូបង្រៀន និង ជួយកសាង បំពាក់គ្រឿងបរិក្ខារដល់សាលាឯកទេស សាលាមបឋមសិក្សា សាលាមធ្យមសិក្សា។ ជាដំបូងសហរដ្ឋអាម៉េរិកបានផ្តល់ជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលគរុកោសល្យបឋមលើកដំបូងរបស់កម្ពុជានៅកំពង់កន្ទួត ព្រមទាំងបានសាងសង់សាលាបឋមសិក្សាចំនួន១៤ និង សាលាមធ្យមសិក្សាចំនួន៥ ផ្សេងទៀត។

នៅពេលនោះ សហរដ្ឋអាម៉េរិកក៏បានផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាមួយចំនួនឱ្យទៅសិក្សានៅសហរដ្ឋអាម៉េរិកលើមុខវិជ្ជាកសិកម្ម សុខភាពសាធារណៈ បច្ចេកទេសក្នុងការប្រើប្រាស់ឧបករណ៍ គ្រឿងម៉ាស៊ីន និង វិស្វកម្ម ។ គម្រោងមួយទៀតគឺការកសាងមណ្ឌលសុខភាព មន្ទីរពេទ្យកុមារ ទន្ទឹមនឹងនេះក៏មានការស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ សហរដ្ឋអាម៉េរិកបានជួយស្ថាបនាផ្លូវជាតិលេខ៤ (ផ្លូវមិត្តភាពកម្ពុជា-សហរដ្ឋអាម៉េរិក) ផ្លូវភ្នំពេញ-ក្រុងព្រះសីហនុ ដែលជាផ្លូវដ៏សំខាន់មួយសម្រាប់ភ្ជាប់ទៅឆ្នេរសមុទ្ររបស់កម្ពុជា។ ការស្ថាបនាផ្លូវនេះបានចំណាយថវិកាអស់ចំនួន២៥ លាន ដុល្លារ សហរដ្ឋអាម៉េរិកគឺជាគម្រោងជំនួយសហប្រតិបត្តិការទោលធំជាងគេដោយមានកម្មករអាម៉េរិក និង ខ្មែរធ្វើការរួមគ្នា។

ជំនួយផ្នែកសេដ្ឋកិច្ចរបស់សហរដ្ឋអាម៉េរិក ដែលបានផ្តល់មកឱ្យប្រទេសកម្ពុជាពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦០ មានដូចតទៅ ៖

- ឆ្នាំ១៩៥៥ ជំនួយផ្នែកសេដ្ឋកិច្ចមានទឹកប្រាក់ចំនួន ២៤ ៦០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៦ ទឹកប្រាក់ជំនួយផ្នែកសេដ្ឋកិច្ចមានចំនួន ២៣ ៨០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៧ ជំនួយផ្នែកសេដ្ឋកិច្ចមានទឹកប្រាក់ចំនួន ១៩ ១០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៨ ជំនួយផ្នែកសេដ្ឋកិច្ចមានទឹកប្រាក់ចំនួន ១៣ ២០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៩ ទឹកប្រាក់ជំនួយផ្នែកសេដ្ឋកិច្ចមានចំនួន ១២ ៥០០ ០០០ ដុល្លារ
- ឆ្នាំ១៩៦០ ជំនួយផ្នែកសេដ្ឋកិច្ចមានចំនួនទឹកប្រាក់ ១០ ៧០០ ០០០ ដុល្លារ។

ជំនួយរបស់សហរដ្ឋអាម៉េរិកដែលបានផ្តល់មកឱ្យកម្ពុជាបានបែងចែកទៅតាមផ្នែកផ្សេងៗគិតជាភាគរយចាប់ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦០ គឺចំណាយលើការងារសាធារណៈ ៤៧.២ % វិស័យកសិកម្ម ១៧.៥ % វិស័យអប់រំ ១៣.៨ % សុខភាពសាធារណៈ ៨.៧ % ផ្នែកនគរបាលស៊ីវិល ៤.៥ % ផ្នែកសហគ្រាស ៣.៥ % មធ្យោបាយនៃការធ្វើទំនាក់ទំនង ២.២ % ផ្នែករដ្ឋបាលសាធារណៈ ០.៩ % និង ចំណាយផ្សេងៗ ១.៧ %។

### ខ-ជំនួយផ្នែកយោធា

ចំពោះជំនួយផ្នែកយោធាគឺពង្រឹងសន្តិសុខ និង ហេដ្ឋារចនាសម្ព័ន្ធ ធ្វើទំនើបកម្មកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជា។ ជំនួយផ្នែកយោធារបស់សហរដ្ឋអាម៉េរិកដែលបានផ្តល់មកឱ្យប្រទេសកម្ពុជាពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៣ មានដូចតទៅ ៖

- ឆ្នាំ១៩៥៥ ទឹកប្រាក់ជំនួយផ្នែកយោធាមានចំនួន ២១ ៣០០ ០០០ ដុល្លារ

- ឆ្នាំ១៩៥៧ ទឹកប្រាក់ជំនួយផ្នែកយោធាមានចំនួន ១៥ ៥០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៨ ទឹកប្រាក់ជំនួយផ្នែកយោធាមានចំនួន ១៥ ៤០០ ០០០ ដុល្លារ
- ឆ្នាំ១៩៥៩ជំនួយផ្នែកយោធាមានចំនួនទឹកប្រាក់ ១៣ ១០០ ០០០ ដុល្លារ
- ឆ្នាំ១៩៦០ ទឹកប្រាក់ជំនួយផ្នែកយោធាមានចំនួន ១២ ០០០ ០០០ ដុល្លារ
- ឆ្នាំ១៩៦១ ទឹកប្រាក់ជំនួយសរុបមានចំនួន ២៦ ៦៦៤ ៧៥៨ ដុល្លារ
- ក្រៅពីនេះសហរដ្ឋអាម៉េរិកបានផ្តល់ជំនួយដែលមិនមាននៅក្នុងគម្រោងគឺមានចំនួនទឹកប្រាក់សរុប ១៥៨ ២៩៩ ដុល្លារ[2]
- ឆ្នាំ១៩៦២ ទឹកប្រាក់ជំនួយសរុបមានចំនួន ២៣ ៩០០ ០០០ ដុល្លារ
- ឆ្នាំ១៩៦៣ ទឹកប្រាក់ជំនួយលើផ្នែកយោធា និង សន្តិសុខផ្ទៃក្នុងសរុបមានចំនួន ១៩ ៣០០ ០០០ដុល្លារ។

សូមបញ្ជាក់ថា នៅមុនឆ្នាំ១៩៥៦ ជំនួយរបស់សហរដ្ឋអាម៉េរិកភាគច្រើនមិនបានយកមកប្រើប្រាស់ដើម្បីធ្វើឱ្យជីវភាពប្រជាជនកម្ពុជាមានលក្ខណៈប្រសើរឡើងនោះឡើយ ជំនួយភាគច្រើនគឺត្រូវបានធ្លាក់ទៅក្នុងកណ្តាប់ដៃបុគ្គល ហើយគេយកប្រាក់ដុល្លារទាំងនោះទៅទិញសម្ភារៈ ដូចជា រថយន្តសម្រាប់ជិះកំសាន្តជាដើម។

នៅក្នុងរយៈពេល៩ ឆ្នាំ គឺពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៣ ប្រទេសកម្ពុជាបានទទួលជំនួយសេដ្ឋកិច្ច និង យោធាពីសហរដ្ឋអាម៉េរិករាប់រយលានដុល្លារ ដែលជំនួយទាំងនេះវាជាការចូលរួមចំណែកមួយយ៉ាងសំខាន់ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ ជំនួយផ្នែកសេដ្ឋកិច្ច យោធា និង បច្ចេកទេសរបស់សហរដ្ឋអាម៉េរិកបានផ្តល់មកឱ្យកម្ពុជាចាប់តាំងពីដំបូងរហូតមកដល់ឆ្នាំ១៩៦៣ ហើយជំនួយនោះចាប់ផ្តើមពីចំនួនច្រើនមកចំនួនតិច[3]។ នៅរាល់ការផ្តល់ជំនួយរបស់សហរដ្ឋអាម៉េរិកគឺមានភ្ជាប់មកជាមួយនូវលក្ខខណ្ឌ។ បើសិនណាជាប្រទេសកម្ពុជាយល់ព្រមចូលរួមក្នុងបក្សសម្ព័ន្ធរបស់សហរដ្ឋអាម៉េរិក ជំនួយនេះនឹងអាចមានទំហំប្រហាក់ប្រហែលនឹងជំនួយដែលសហរដ្ឋអាម៉េរិកផ្តល់ឱ្យទៅប្រទេសជិតខាងកម្ពុជា។ ដោយសារប្រទេសកម្ពុជាឈរលើមូលដ្ឋាននៃនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធនោះកម្ពុជាមិនអាចនឹងទៅចូលរួមជាមួយប្លុកនៃមនោគមវិជ្ជាណាមួយបានឡើយ។

ហេតុនេះកម្ពុជានឹងមិនបានទទួលផលផ្នែកជំនួយទេ ទុកណាជានៅលើផែនការសេដ្ឋកិច្ចក៏ដោយបើប្រៀបប្រដូចទៅនឹងប្រទេសដែលចូលក្នុងបក្សសម្ព័ន្ធណាមួយនោះ[4]។ ចំណែកឯសម្ព័ន្ធមិត្តរបស់សហរដ្ឋអាម៉េរិកនៅឥណ្ឌូចិន ដូចជា វៀតណាមខាងត្បូង និង ឡាវសេរីបានទទួលជំនួយកាន់តែច្រើនឡើង។ តែទោះជាយ៉ាងនេះក្តីការធ្វើឱ្យបានសម្រេចផែនការពីរឆ្នាំរបស់សង្គមរាស្ត្រនិយមពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៥៨ គឺអាស្រ័យដោយជំនួយបរទេសរហូតដល់ទៅ៩២ ភាគរយ ដូចនេះថវិកាជាតិមានតែ៨ ភាគរយតែប៉ុណ្ណោះ។ ប៉ុន្តែការដាក់ផែនការប្រាំឆ្នាំលើកទី១ បន្តមកទៀតគេសង្កេតឃើញថាចំនួនថវិកាជាតិបានឡើងរហូតដល់ទៅ៦៨ ភាគរយ ឯជំនួយបរទេសធ្លាក់មកនៅត្រឹម

---

[2] *Le Programme de l'aide économique américaine au Cambodge 1955-1959,* 1960. P. 21

[3] *Ibid.,*

[4] ប្រទេសកម្ពុជាជួយដោយខ្លួនឯង ភ្នំពេញ ឆ្នាំ១៩៦៣ ទំព័រ២-៦

តែ ៣២ ភាគរយ។ ផែនការប្រាំឆ្នាំលើកទី២កម្ពុជានឹងគ្រោងថវិកាជាតិចំនួន៩០ភាគរយ[5]។ ដោយប្រទេសកម្ពុជាចង់រក្សាឱ្យបាននូវនយោបាយអព្យាក្រឹតរបស់ខ្លួននោះ កម្ពុជាតែងតែបដិសេធមិនចូលរួមជាមួយនឹងអង្គការសេអាតូដែលមានចរិតជាអង្គការសម្ព័ន្ធភាពយោធា។ ត្រង់ចំណុចនេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងឱកាសនៃព្រះរាជដំណើរទស្សនកិច្ចរបស់សម្តេចព្រះនរោត្តម សីហនុ ទៅកាន់ប្រទេសហ្វីលីពីននាឆ្នាំ១៩៥៦ដោយព្រះអង្គបានថ្លែងការពារយ៉ាងដាច់ខាតចំពោះជំហរអព្យាក្រឹតរបស់ព្រះអង្គ[6]។

គួររម្លឹកផងដែរថា កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៥៥ លោករដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិក John Foster Dulles បានមកបំពេញទស្សនកិច្ចនៅក្រុងភ្នំពេញដើម្បីទទួលនូវការដាក់បញ្ចូលប្រទេសកម្ពុជាទៅក្នុងអង្គការសេអាតូ ប៉ុន្តែ ត្រូវបានបដិសេធដោយសម្តេចព្រះនរោត្តម សីហនុ[7]។ ការបដិសេធបែបនេះ គឺព្រះអង្គបានសម្អាងទៅលើការសន្យារបស់កម្ពុជានៅឯសន្និសីទក្រុងហ្សឺណែវដែលកម្ពុជាបានប្រកាន់យកជំហរអព្យាក្រឹត។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៦៣ សម្តេចព្រះនរោត្តម សីហនុ បានប្រកាសឈប់ទទួលយកជំនួយរបស់សហរដ្ឋអាម៉េរិក។ បន្ទាប់មកទៀតនៅថ្ងៃទី២៩-៣១ ខែធ្នូ ឆ្នាំ១៩៦៣ ដដែលក្នុងឱកាសសមាជជាតិលើកទី១៦ បានឯកភាពទាំងស្រុងលើការបដិសេធនូវជំនួយយោធា និងស៊ីវិលទាំងអស់របស់សហរដ្ឋអាម៉េរិក[8] ។ ការប្រកាសបដិសេធមិនទទួលយកជំនួយសហរដ្ឋអាម៉េរិកនាឆ្នាំ១៩៦៣ ពីសំណាក់ប្រទេសកម្ពុជាបានធ្វើឱ្យសហរដ្ឋអាម៉េរិកបង្កើនការគាបសង្កត់មកលើប្រទេសកម្ពុជា តាមរយៈការផ្តល់អាវុធឱ្យកម្លាំងចលនាខ្មែរសេរី និង ការរំលោភមកលើដែនអាកាសកម្ពុជាពីសំណាក់យន្តហោះយោធាថៃ និង វៀតណាមខាងត្បូង។ ការប្រកាន់យកនយោបាយអព្យាក្រឹតបានធ្វើឱ្យកម្ពុជាទទួលរងសម្ពាធពីមហាអំណាចមូលធននិយម ពិសេសគឺសហរដ្ឋអាម៉េរិក។ ទង្វើនេះបានបង្ហាញឱ្យឃើញពីការគាំទ្ររបស់សហរដ្ឋអាម៉េរិកចំពោះប្រទេសថៃ និង វៀតណាមខាងត្បូងដើម្បីដាក់គំនាបមកលើប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៩ លោកសឺន សាន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាបានថ្លែងជម្រាបទៅកាន់អ្នកតំណាងរបស់សហរដ្ឋអាម៉េរិកដែលបានចោទប្រកាន់ថា មានកងទ័ពវៀតមិញឆ្លងកាត់ទឹកដីកម្ពុជាដើម្បីចូលទៅវៀតណាមខាងត្បូង លោក សឺន សាន បានថ្លែងគូសបញ្ជាក់ថា ប្រទេសកម្ពុជាសព្វថ្ងៃ (សម័យសង្គមរាស្ត្រនិយម) ជាព្រះរាជាណាចក្រអព្យាក្រឹត បើដូច្នេះយើងមិនអាចទៅកាន់របបកុម្មុយនីស្តបានទេ នយោបាយអព្យាក្រឹតរបស់យើងគឺត្រូវបានប្រកាន់យកតាំងពីសន្និសីទក្រុងហ្សឺណែវមកម្ល៉េះ ហើយមិនមែនបរទេសណាមួយមកបង្ខំឱ្យកម្ពុជាដើរតាមមាគ៌ានេះដែរ។ ចំពោះការចោទប្រកាន់ពីសំណាក់លោកសេរីថា កម្ពុជាប្រកាន់យកនយោបាយអព្យាក្រឹត

---

[5] *ព្រះសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋទ្រង់ថ្លែងក្នុងឱកាសសម្ពោធពិពណ៌អចិន្ត្រៃយ៍ថ្មីនៃសមិទ្ធិសង្គម* ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៤ ទំព័រ៤

[6] Norodom Sihanouk, *La c.i.a. contre le Cambodge,* François Maspéro pour l´édition française, Paris, p. 63-64

[7] Raoul M. Jennar, *Les clés du Cambodge,* Faits et chiffres, repères historiques, profiles cambodgiens, cartes, Maisonneuve et Larose, 1995, p. 58

[8] *Ibid.,* p. 63

ដែលលម្អៀងទៅរកកុម្មុយនីស្ត លោក សឺន សាន ក៏បានឆ្លើយតបដោយលោកបានប្រៀបធៀបថា *ប្រទេសកម្ពុជាប្រៀបបានដូចជាទូកមួយដែលយើងធ្វើដំណើរនៅចំកណ្តាលស្ទឹង ឬ កណ្តាលទន្លេ។ ប៉ុន្តែ តាំងពីឆ្នាំ១៩៥៤ មក នៅត្រើយខាងឆ្វេងមិនដែលបានដោលទូកយើងទេ បើយើងត្រូវរងគ្រោះច្រើនតែត្រូវបាញ់ពីខាងស្តាំទៅវិញ ហេតុដូច្នេះហើយបើកាលណាគេបាញ់ពីត្រើយខាងស្តាំទូកនោះរត់ចៀសបន្តិច ហើយប្រឆាំងទៅវិញ។ បើគ្មានការប្រឆាំងឆ្វេងទេ យើងនៅកាន់អព្យាក្រឹតពិតអញ្ចឹងសុំតែត្រើយខាងស្តាំនោះកុំបាញ់យើងទៀត*[9]។

ចាប់ពីការបដិសេធនូវជំនួយនេះមកស្ថានភាពនៃទំនាក់ទំនងរវាងកម្ពុជា និង សហរដ្ឋអាម៉េរិក កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៦៤ បាតុកម្មប្រឆាំងនឹងស្ថានទូតសហរដ្ឋអាម៉េរិក និង អង់គ្លេសបានកើតឡើងនៅក្រុងភ្នំពេញ[10]។ នៅចុងបញ្ចប់ប្រទេសកម្ពុជាបានកាត់ផ្តាច់ចំណងការទូតជាមួយនឹងសហរដ្ឋអាម៉េរិក នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦៥។

## ផ្នែកទី ២. កម្ពុជាបដិសេធជំនួយសហរដ្ឋអាម៉េរិក

## II-ការប្រែប្រួលស្ថានភាពនយោបាយនៅឥណ្ឌូចិនទសវត្សរ៍ឆ្នាំ១៩៦០

### ១-ស្ថានភាពនៃទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិកពីឆ្នាំ១៩៦០-១៩៧០

នៅទសវត្សរ៍ឆ្នាំ១៩៦០ ជារយៈពេលប្រកបទៅដោយភាពរំជើបរំជួលនៅឥណ្ឌូចិន គឺសហរដ្ឋអាម៉េរិកបានចូលពាក់ព័ន្ធកាន់តែជ្រៅក្នុងសង្គ្រាមវៀតណាម ហើយសង្គ្រាមស៊ីវិលនៅប្រទេសឡាវកាន់តែរីករាលដាលធំឡើងៗ។ គោលជំហរនយោបាយការបរទេសរបស់សហរដ្ឋអាម៉េរិកគឺការទប់ទល់នឹងឥទ្ធិពលរបស់ប្រទេសចិន និង ការធានាឱ្យបានជ័យជម្នះលើវៀតណាមខាងជើងគឺជាអាទិភាពសំខាន់។

សហរដ្ឋអាម៉េរិកបានចងសម្ព័ន្ធជាមួយប្រទេសថៃ និង ប្រទេសវៀតណាមខាងត្បូង ហើយសង្ឃឹមថានឹងដើរតួនាទីក្នុងការកែលម្អទំនាក់ទំនងរវាងសហរដ្ឋអាម៉េរិក-កម្ពុជា និង ជាមួយប្រទេសជិតខាង។ សម្តេចព្រះនរោត្តម សីហនុ ដែលពេលនោះជាព្រះប្រមុខរដ្ឋបានប្តេជ្ញាយ៉ាងមុតមាំក្នុងការប្រកាន់នយោបាយអព្យាក្រឹតគឺព្រះអង្គមានគោលបំណងបញ្ចៀសប្រទេសកម្ពុជាមិនឱ្យពាក់ព័ន្ធទៅនឹងសង្គ្រាមវៀតណាម។ មិនតែប៉ុណ្ណោះព្រះអង្គក៏មានការព្រួយបារម្ភនៅពេលប្រទេសវៀតណាមខាងជើង និង វៀតណាមខាងត្បូងរួមគ្នាតែមួយ។

ក្នុងការគិតគូរថា ត្រូវរក្សានូវអធិបតេយ្យភាពទឹកដីនៃប្រទេសកម្ពុជា និង មានការសង្ស័យទៅលើចេតនារបស់ប្រទេសថៃ និង វៀតណាមខាងត្បូង សម្តេចព្រះនរោត្តម សីហនុ បានបន្តការធ្វើទំនាក់ទំនងជាមួយមហាអំណាចទាំងពីរគឺសហរដ្ឋអាម៉េរិក និង សហភាពសូវៀត ។ ព្រះអង្គតែងចាត់ទុកផលប្រយោជន៍ និង អត្តសញ្ញាណរបស់ប្រទេសកម្ពុជាធំជាងអ្វីទាំងអស់។

សម្រាប់សហរដ្ឋអាម៉េរិកគិតថា ខ្លួនអាចទទួលយកបាននយោបាយអព្យាក្រឹតកម្ពុជា លុះណាតែរដ្ឋាភិបាលកម្ពុជាពិតជានៅអព្យាក្រឹត ហើយជាផ្លូវការមិនលម្អៀងទៅរកប្រទេសកុម្មុយនីស្ត។ ចំណែកស្ថានការណ៍នៅប្រទេសឡាវ ដែលពួកកុម្មុយនីស្ត Pathet Lao កំពុងតែមានប្រៀប ហើយ

---

[9] កំណត់ហេតុប្រជុំសភា នៅក្នុងរាជកិច្ចលេខ២៨ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៥៩ ទំព័រ៤៩០៥

[10] Raoul M. jennar, *Les clés du Cambodge, op. cit.*, p. 64

វៀតណាមខាងជើងកំពុងតែបញ្ជូនទាហាន និង គ្រឿងផ្គត់ផ្គង់មកភាគខាងត្បូង ហេតុនេះសម្តេចព្រះនរោត្តម សីហនុ បានអំពាវនាវឱ្យមានការកោះប្រជុំសន្និសីទក្រុងហ្សឺណែវ ហើយព្រះអង្គសង្ឃឹមថា សន្និសីទនោះនឹងអាចដោះស្រាយស្ថានភាពទាំងនោះបាន ។ នៅឆ្នាំ១៩៦១ សហរដ្ឋអាម៉េរិក សាធារណរដ្ឋប្រជាមានិតចិន សហភាពសូវៀត អង់គ្លេស បារាំង រួមទាំងប្រទេសចំនួន ១៤ ផ្សេងទៀត បានចូលរួមពិភាក្សា ។ មួយឆ្នាំក្រោយមកការចរចាបានឈានដល់ការព្រមព្រៀងគ្នាដែលអំពាវនាវឱ្យប្រទេសឡាវក្លាយជាប្រទេសមានសន្តិភាព អព្យាក្រឹតភាព ឯករាជ្យ និង អធិបតេយ្យ។

មកដល់ឆ្នាំ១៩៦២ ជំហររបស់សហរដ្ឋអាម៉េរិកចំពោះប្រទេសកម្ពុជាត្រូវបានបែងចែកទៅជាពីរក្រុម។ ក្រុមមួយមានជំនឿថា សម្តេចព្រះនរោត្តម សីហនុ នឹងភ្ជាប់ព្រះអង្គទៅនឹងពួកកុម្មុយនីស្ត។ មួយក្រុមទៀតយល់ថា ដើម្បីផលប្រយោជន៍សហរដ្ឋអាម៉េរិកគេមិនត្រូវធ្វើឱ្យប្រទេសកម្ពុជានៅឯកោនោះទេ ។ អ្នកដែលគាំទ្រខ្លាំងរបស់ក្រុមទី២ គឺលោកព្រឹទ្ធសមាជិកសភាអាមេរិក Mike Mansfield ដែលបានមកធ្វើទស្សនកិច្ចប្រទេសកម្ពុជានៅចុងឆ្នាំ១៩៦២ ។ លោកព្រឹទ្ធសមាជិករូបនេះជាអ្នកជំនាញផ្នែកអាស៊ី ហើយក្រោយមកលោកបានក្លាយជាឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកយូរជាងគេប្រចាំនៅប្រទេសជប៉ុន ។ លោក Mike Mansfield បានពិភាក្សាផ្តល់យោបល់ដោយផ្ទាល់ជាមួយលោកប្រធានាធិបតី Kennedy, Johnson និង លោកប្រធានាធិបតី Nixon ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង ឆ្នាំ១៩៧០ ដែលគាត់បានប្រឆាំងទៅនឹងការជាប់ពាក់ព័ន្ធរបស់សហរដ្ឋអាម៉េរិកនៅក្នុងសង្គ្រាមវៀតណាម ។

បើទោះជាមានការធានាអះអាងដោយផ្ទាល់ពីលោកប្រធានាធិបតី Kennedy ថា សហរដ្ឋអាម៉េរិកគាំទ្រអព្យាក្រឹតនៃប្រទេសកម្ពុជា ហើយមិនគាំទ្រពួកប្រឆាំងក្តី ប៉ុន្តែ សម្តេចព្រះនរោត្តម សីហនុ នៅតែអំពាវនាវឱ្យមានការបញ្ឈប់ជាបន្ទាន់នូវជំនួយរបស់សហរដ្ឋអាម៉ារិកដែលមានតម្លៃប្រហែល១៥ ភាគរយ នៃថវិកាជាតិកម្ពុជា ។ នៅខែមករា ឆ្នាំ១៩៦៤ សហរដ្ឋអាម៉េរិកបានចាប់ផ្តើមកាត់បន្ថយបុគ្គលិករបស់ខ្លួនចេញពីក្រុងភ្នំពេញ ហើយលោក នង គឹមនី ដែលជាឯកអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាម៉េរិកត្រូវបានហៅត្រឡប់មកប្រទេសកម្ពុជាវិញ ។ ចំណែកឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកលោក Philip D. Sprouse ក៏បានវិលត្រឡប់ទៅកាន់សហរដ្ឋអាម៉េរិកវិញដែរ។

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៦៤ លោក Randolph A. Kidder ត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅកម្ពុជា ប៉ុន្តែសម្តេចព្រះនរោត្តម សីហនុ បដិសេធមិនទទួលសារតាំងរបស់លោក[11]។ នៅដំណាច់ឆ្នាំ១៩៦៤ មានតំណាងសហរដ្ឋអាម៉េរិកតែចំនួន១២ នាក់ប៉ុណ្ណោះនៅកម្ពុជាដែលកាលពីមួយឆ្នាំមុនមានចំនួន៣០០ នាក់។ នៅខែឧសភា ឆ្នាំ១៩៦៥ ទំនាក់ទំនងកម្ពុជា និង សហរដ្ឋអាម៉េរិកត្រូវបានកាត់ផ្តាច់ ។ ភាពតានតឹងនៅតែកើតមានជាបន្តមកទៀត ដោយសហរដ្ឋអាម៉េរិកបានចោទប្រកាន់ថា ពួកកុម្មុយនីស្តវៀតណាមកំពុងដឹកជញ្ជូនផ្គត់ផ្គង់តាមកំពង់ផែក្រុងព្រះសីហនុ ។

### ២-កម្ពុជាក្នុងដំណាក់កាលនៃសង្គ្រាមវៀតណាម

---

[11] *ខួបលើកទី៦០ ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-អាម៉េរិក (១៩៥០-២០១០)* បោះពុម្ពដោយស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំក្រុងភ្នំពេញ ឆ្នាំ២០១០ ទំព័រ៤៧

ដំណើរទេសចរណ៍កិច្ចរបស់លោកជំទាវ Jacqueline Kennedy មកប្រទេសកម្ពុជានៅខែវិច្ឆិកា ឆ្នាំ១៩៦៧ ហាក់មានការប្រែប្រួលនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ។ នៅពេលនោះសម្តេចព្រះនរោត្តម សីហនុ បានរៀបចំទទួលស្វាគមន៍លោកជំទាវ Jacqueline Kennedy ជាភ្ញៀវពិសេស ដោយលោកជំទាវ គឺជាជនជាតិអាម៉េរិកដំបូងគេដោយទទួលបានកិត្តិយសថ្នាក់រដ្ឋខ្ពស់តាំងតែពីមាន ការកាត់ផ្តាច់ចំណងការទូតនៃប្រទេសទាំងពីរ។

បន្ទាប់មក នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៨ លោក Chester A. Bowles ជាបេសកជនរបស់ប្រធានាធិបតីសហរដ្ឋអាម៉េរិកបានធ្វើដំណើរមកក្រុងភ្នំពេញដើម្បីពិភាក្សា ស្តីពីការកម្រិត វត្តមានកងទ័ពវៀតកុងនៅលើទឹកដីកម្ពុជា និង កង្វល់របស់សម្តេចព្រះនរោត្តម សីហនុ លើបូរណភាពទឹកដីនៃប្រទេសកម្ពុជា ។ លោកប្រធានាធិបតីសហរដ្ឋអាម៉េរិក Nexon បានចូលកាន់តំណែងនៅ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៩ ។ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៦៩ សហរដ្ឋអាម៉េរិកបានចេញសេចក្តីប្រកាសទទួលស្គាល់អធិបតេយ្យភាព ឯករាជ្យ អព្យាក្រឹតភាព និង បូរណភាពទឹកដីនៃប្រទេសកម្ពុជា។

ទោះជាយ៉ាងណាក៏ដោយទំនាក់ទំនងការទូតរវាងកម្ពុជា និង សហរដ្ឋអាម៉េរិកនាពេលនោះនៅតែមិនមានភាពរលូន ។ ភាពកកាំកកូសនេះបានបន្តរហូតដល់លោក លន់ នល់ បានទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីប្រមុខរដ្ឋនៃប្រទេសកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ នៅពេលនោះប្រទេសកម្ពុជាបានក្លាយជាសាធារណរដ្ឋដែលស្និទ្ធទៅនឹងសហរដ្ឋអាម៉េរិក ហើយកម្ពុជាបានប្រឈមយ៉ាងពេញទំហឹងទៅនឹងចលនាកុម្មុយនីស្តខ្មែរ និង វៀតណាម ។ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមវៀតណាម ហើយសង្គ្រាមនៅកម្ពុជាបានក្លាយជាសង្គ្រាមស៊ីវិលអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ។

សរុបមកទំនាក់ទំនងការទូតរវាងកម្ពុជា និង សហរដ្ឋអាម៉េរិកនាសម័យក្រោយកម្ពុជាទទួលបានឯករាជ្យពីរបបអាណាព្យាបាលបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយជាពិសេសនៅក្នុងសម័យសង្គមរាស្ត្រនិយមពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ មិនសូវមានភាពរលូនឡើយ។ ចាប់តាំងពីកម្ពុជាបានបដិសេធមិនទទួលយកជំនួយសហរដ្ឋអាម៉េរិកនៅឆ្នាំ១៩៦៣ មក ទំនាក់ទំនងកម្ពុជា-សហរដ្ឋអាម៉េរិកតែងតែមានភាពកកាំកកូសជាបន្តបន្ទាប់ ជាក់ស្តែងនៅឆ្នាំ១៩៦៥ ទំនាក់ទំនងការទូតរវាងកម្ពុជា និង សហរដ្ឋអាម៉េរិកបានឈានទៅដល់កម្រិតមួយធ្ងន់ធ្ងររហូតមានការផ្តាច់ចំណងការទូត នៃប្រទេសទាំងពីរទៀតផង។ លុះមកដល់ឆ្នាំ១៩៦៩ ទើបស្ថានភាពនៃទំនាក់ទំនងការទូតរបស់ប្រទេសទាំងពីរត្រូវបានស្តារឡើងវិញ។ ហេតុការណ៍ដែលធ្វើឱ្យមានភាពមិនរលូននៅក្នុងទំនាក់ទំនងការទូតរវាងកម្ពុជា និង សហរដ្ឋអាម៉េរិកនៅពេលនោះ គឺសហរដ្ឋអាម៉េរិកបានផ្តល់ជំនួយយោធាជាច្រើនមកឱ្យប្រទេសកម្ពុជា ដែលជំនួយនោះសហរដ្ឋអាម៉េរិកមានគោលបំណងចង់ឱ្យប្រទេសកម្ពុជាក្លាយទៅជាប្រទេសមួយដែលគាំទ្រលោកសេរីដើម្បីប្រឆាំងនឹងការរីករាលដាល នៃលទ្ធិកុម្មុយនីស្តនៅភូមិភាគអាស៊ីអាគ្នេយ៍។ ជាពិសេស សហរដ្ឋអាម៉េរិកចង់ឱ្យប្រទេសកម្ពុជាចូលជាសមាជិកអង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ ឬ គេហៅថា សេអាតូ។ ដោយសារនៅសម័យសង្គមរាស្ត្រនិយមកម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រឹត ហេតុនេះកម្ពុជាបានប្រកាន់យកបន្ទាត់នយោបាយអន្តរជាតិកណ្តាលមួយមានន័យថា កម្ពុជាអាចធ្វើទំនាក់ទំនងការទូតជាមួយប្រទេសទាំងឡាយនៅក្នុងសកលលោកមិនបែងចែកថា ប្រទេសនោះជាប្រទេសប្រកាន់លទ្ធិសេរី ឬ កុម្មុយនីស្តនោះឡើយ។ ការប្រកាន់ជំហររបស់កម្ពុជា

បែបនេះបានធ្វើឱ្យមេដឹកនាំលោកខាងលិច ជាពិសេសសហរដ្ឋអាម៉េរិកមិនព្រមផ្តល់ការគាំទ្រពេញលេញដល់ប្រទេសកម្ពុជា។

## សន្និដ្ឋាន

បន្ទាប់ពីទទួលបានឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាត្រូវប្រឈមទៅនឹងបញ្ហាជាច្រើន ជាពិសេសប្រឈមនឹងបញ្ហាការពង្រឹងឯកភាពជាតិ សេដ្ឋកិច្ច និង ការការពារជាតិ។ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនាពេលនោះកម្ពុជាត្រូវពឹងផ្អែកទៅលើជំនួយពីបរទេសមួយភាគធំ ។ ការស្វែងរកជំនួយនេះទៀតសោតកម្ពុជាក៏ត្រូវទទួលរង នូវសម្ពេធនៃមនោគមវិជ្ជាធំពីរនៅក្នុងសកលលោកនាពេលនោះគឺមនោគមវិជ្ជាសេរី ដែលតំណាងដោយសហរដ្ឋអាម៉េរិកនិងមនោគមវិជ្ជាកុម្មុយនីស្តតំណាងដោយសហភាពសូវៀត។ អាស្រ័យដោយសកលលោកមានការដណ្តើមឥទ្ធិពលគ្នាបែបនេះ កម្ពុជាបានជ្រើសរើសយកនយោបាយអព្យាក្រឹតមកធ្វើជាមូលដ្ឋានគ្រឹះ នៃនយោបាយការបរទេសរបស់ខ្លួន។ នយោបាយនេះជាផ្លូវមួយសម្រាប់ឱ្យកម្ពុជាមានលទ្ធភាពអាចទៅធ្វើទំនាក់ទំនងជាមួយប្រទេស ដែលប្រកាន់លទ្ធិសង្គមនិយមផង និង ទំនាក់ទំនងជាមួយប្រទេសដែលប្រកាន់លទ្ធិសេរីផងដែរ។

ទំនាក់ទំនងជាផ្លូវការរវាងកម្ពុជា-សហរដ្ឋអាម៉េរិក គឺត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥០។ បន្ទាប់មកសហរដ្ឋអាម៉េរិកបានចាប់ផ្តើមផ្តល់ជំនួយមកឱ្យកម្ពុជាទាំងជំនួយផ្នែកសេដ្ឋកិច្ច និង ជំនួយផ្នែកយោធា។ ជំនួយរបស់សហរដ្ឋអាម៉េរិកបានផ្តោតទៅលើវិស័យអប់រំ ដូចជា ការកសាងសាលារៀន ជាដើម។ ជំនួយផ្នែកអភិវឌ្ឍន៍ជនបទ និង ស្តារហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រព័ន្ធប្រឡាយសម្រាប់វិស័យកសិកម្ម។ ចំណែកជំនួយយោធារបស់សហរដ្ឋអាម៉េរិកបានផ្តល់ជាប្រាក់បៀវត្សរ៍ដល់យោធាកម្ពុជា និង ផ្តល់សម្ភារៈយោធាមានគ្រឿងសព្វាវុធ ដូចជា កាំភ្លើង រថយន្តយោធា  រថគ្រោះ ជាដើម ។ ដោយផ្អែកទៅលើនយោបាយអព្យាក្រឹតកម្ពុជាបានទៅធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសកុម្មុយនីស្តមានសហភាពសូវៀត សាធារណរដ្ឋប្រជាមានិតចិន ជាដើម ។ ទន្ទឹមនឹងសហរដ្ឋអាម៉េរិកមកបង្កើតទំនាក់ទំនងការទូតជាមួយកម្ពុជា សហរដ្ឋអាម៉េរិកបានស្នើឱ្យកម្ពុជាចូលជាសមាជិករបស់អង្គការសេអាតូ (អង្គការសន្ធិសញ្ញាប្រឆាំងនឹងការរីករាលដាលនៃលទ្ធិកុម្មុយនីស្តនៅអាស៊ីអាគ្នេយ៍) ដែលបានបង្កើតឡើងនៅឆ្នាំ១៩៥៤ ។ នៅពេលនោះកម្ពុជាបានបដិសេធមិនព្រមចូលជាសមាជិករបស់អង្គការមួយនេះ ដោយកម្ពុជាបានអះអាងថា ខ្លួនជាប្រទេសអព្យាក្រឹត។

នៅពេលដែលកម្ពុជាបដិសេធមិនព្រមចូលជាសមាជិកអង្គការសេអាតូ ហើយកម្ពុជាទៅបង្កើតទំនាក់ទំនងការទូតជាមួយសហភាពសូវៀត សាធារណរដ្ឋប្រជាមានិតចិន បានធ្វើឱ្យទំនាក់ទំនងរវាងកម្ពុជា-សហរដ្ឋអាម៉េរិកចាប់ផ្តើមរកាំរកូស ហើយសហរដ្ឋអាម៉េរិកមិនបានគាំទ្រកម្ពុជាឱ្យបានពេញលេញឡើយ។ ក្នុងបរិបទនៃសង្គ្រាមត្រជាក់ និង ការប្រកាន់យកនយោបាយការបរទេសមិននឹងននៅពេលនោះកម្ពុជាហាក់ឃ្លាតចេញពីប្រទេសក្នុងប្លុកសេរី ហើយបានបាត់បង់ឱកាសក្នុងការទទួលយកជំនួយមកអភិវឌ្ឍន៍ប្រទេសជាតិរបស់ខ្លួន។

**គន្ថនិទ្ទេស**

**ឯកសារជាភាសាខ្មែរ**

១-ព្រះរាជដំណើរព្រះបាទនរោត្តម សីហនុ ឧបយុវរាជស្តេចយាងទៅកាន់ប្រទេសចិនសាធារណរដ្ឋប្រជាមានិត ខែកុម្ភៈ ឆ្នាំ១៩៥៦។

២-វិភាគបទនៃសន្និសីទរបស់សម្តេចព្រះនរោត្តម សីហនុ នៅកំពតថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៥៦។

៣-ទស្សនាការជាមិត្តភាពរបស់ព្រះបាទនរោត្តម សីហនុ ទៅកាន់សហភាពសូវៀត ខែកក្កដា ឆ្នាំ១៩៥៦។

៤-*រាជកិច្ច* លេខ២១ ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៧។

៥-*កំណត់ហេតុប្រជុំសភា* នៅក្នុងរាជកិច្ចលេខ២៨ ចេញផ្សាយថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៥៩។

៦-*ប្រទេសកម្ពុជាជួយដោយខ្លួនឯង* ភ្នំពេញ ឆ្នាំ១៩៦៣។

៧-*ព្រះសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋទ្រង់ថ្លែងក្នុងឱកាសសម្ពោធពិពណ៌អចិន្ត្រៃយ៍ថ្មីនៃសមិទ្ធិសង្គម* ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៤។

៨-នរោត្តម សីហនុ *អនុស្សាវរីយ៍ផ្អែមល្ហែម និង ជូរចត់* (បកប្រែដោយ ន.រណរង្គ) ឆ្នាំ១៩៩៣។

៩-*ខួបលើកទី៦០ ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-អាម៉េរិក (១៩៥០-២០១០)* បោះពុម្ពដោយស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំក្រុងភ្នំពេញ ឆ្នាំ២០១០។

**ឯកសារជាភាសាបរទេស**

១-*Le Programme de l'aide économique américaine au Cambodge 1955-1959,* 1960

២-M. Raoul Jennar, *Les clés du Cambodge,* Faits et chiffres, repères historiques, profiles cambodgiens, cartes, Maisonneuve et Larose, 1995.

៣ - Norodom Sihanouk. *La c.i.a contre le Cambodge,* François Maspéro pour l'édition française, Paris, 1973.